**សំណួររបស់អ្នកចូលរួមប្រជុំ ទៅកាន់ គណកម្មាធិការកែទម្រង់សាលារៀន (SRC)**

១. **តើគេបានធ្វើអ្វីខ្លះ ដើម្បីឲ្យសិស្សានុសិស្ស ទទួលការជួយការពារពីប៉ូលីសសាលា ហើយអាចទៅជួបនឹងគិលានុបដ្ឋាករបស់សាលាបាន?**

**ប៉ូលីសសាលា៖**

- ប៉ូលីសសាលាសហការយ៉ាងជិតស្និតជាមួយ នាយកសាលា និងប៉ូលីសក្រុងហ្វីឡាដែលហ្វ្យា ដើម្បីរៀបចំឲ្យមានជំនួយផ្នែកសន្តិសុខនៅសាលា
- នាយកសាលា និងប៉ូលីសសាលា បានទទួលការហ្វឹកហ្វឺនអំពី ច្បាប់ និង នីតិវិធី ដែលបានពន្យល់នៅក្នុង ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស៖ http://philasd.org/offices/administration/policies/118.html

  ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស ដែលបានបកប្រែជាភាសាផ្សេងៗ អាចទាញយកពីវ៉ិបសៃនេះ៖ https://webapps.philasd.org/tdm/search/Khmer/yxzwCode#results
- ចំពោះការបារម្ភដែលបានកើតឡើងភ្លាមៗដែលទាក់ទងនឹងការសម្លុតធ្វើបាប លោកអ្នកអាចទាក់ទងតាមខ្សែទូរស័ព្ទសម្រាប់ ការសម្លុតធ្វើបាប និង សន្តិសុខ លេខ ២១៥-៤០០-៧២៣៣។ លោកអ្នកក៏អាចបំពេញលិខិតតាមអ៊ិនធ័រណិតបានដែរ www.philasd.org/language/khmer/-allegation-of-bullying។

** ជាការសំខាន់ណាស់ដែលសិស្សានុសិស្សរាយការណ៍ជាបន្ទាន់ អំពីបញ្ហាអ្វីមួយដែលពួកគេមាន។ សិស្សានុសិស្សអាចទៅរក គ្រូ ESOL អ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា (BCA) ឬ អ្នកផ្តល់ឱវាទនៅសាលា បើសិនជាពួកគេត្រូវការជំនួយក្នុងការរាយការណ៍ពីការបារម្ភរបស់ពួកគេ។*

**គិលានុបដ្ឋាកសាលា៖**

- សិស្សគ្រប់រូបអាចជួបជាមួយគិលានុបដ្ឋាកសាលា។ ទោះជាយ៉ាងនេះក្តី ប្រហែលជាមិនអាចជួបបានជារៀងរាល់ថ្ងៃនោះទេ។ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ធ្វើតាមការណែនាំដែល ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា បានកំណត់ឲ្យគឺ គិលានុបដ្ឋាកម្នាក់ សម្រាប់សិស្សានុសិស្ស ១,៥០០ នាក់។
- គេផ្តល់ឲ្យសាលានូវតារាងបត់ អំពីច្បាប់ជំនួយបឋម (First Aid Policy flipchart) ហើយសមាជិកបុគ្គលិកទាំងអស់ទទួលខុសត្រូវក្នុងការអនុវត្តតាមការណែនាំដែលគេបានផ្តល់ឲ្យនៅក្នុងតារាងបត់នេះ។
- ចំពោះសិស្សានុសិស្សដែលត្រូវការជំនួយសុខភាព គម្រោងការព្យាបាលត្រូវបានរៀបចំឡើងដោយគិលានុបដ្ឋាកសាលាដោយមានការសហការជាមួយបុគ្គលិករបស់សាលាទាំងមូល។ ដើម្បីឲ្យដឹងថាសិស្សត្រូវការជំនួយសុខភាព មាតាបិតាត្រូវបំពេញ «លិខិតសម្រាប់ទាក់ទងនៅពេលមានអាសន្ន» ហើយប្រគល់ទៅឲ្យនាយកសាលា។ លិខិតនេះជាភាសាខ្មែរមាននៅក្នុងវ៉ិបសៃ៖ https://webapps.philasd.org/tdm/search/Khmer/wyzxEmerg#results

**២. តើត្រូវធ្វើអ្វីខ្លះដើម្បី ពង្រីក និង គាំទ្រ ការសហការរវាង ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា និង អង្គការ វប្បធម៌/ភាសា ចម្រុះ នៅក្នុងសហគមន៍?**

- ការិយាល័យគាំទ្រគ្រួសារដែលនិយាយភាសាចម្រុះ នៃការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និងសហគមន៍ បានបង្កើត និង រក្សា ការសហការយ៉ាងជិតស្និតជាមួយអង្គការដែលបម្រើ ជនអន្តោប្រវេសន៍/ជនភៀសខ្លួន ចូលរួមក្នុងអង្គប្រជុំ ដោយទៀក (អ្នកដឹកនាំ សហគមន៍ និងសាសនា) និងរួមគ្នា (សហការ) ហើយទាក់ទងជាមួយអង្គការដែលបម្រើ ជនអន្តោប្រវេសន៍/ជនភៀសខ្លួន និងអ្នកសំខាន់ៗនៅក្នុងសហគមន៍ ដើម្បីឲ្យពួកគេបានដឹងឲ្យទាន់សភាពការណ៍អំពី ព័ត៌មាន ជំនួយ និងឱកាសផ្សេងៗ របស់ក្រសួង ព្រមទាំងជំនួយពី ទីក្រុង រដ្ឋ និង ជាតិ។ តាមរយៈនៃ កម្មវិធី *Welcome Wagon* ការិយាល័យគាំទ្រគ្រួសារដែលនិយាយភាសាចម្រុះ ផ្តល់ការហ្វឹកហ្វឺនដោយផ្ទាល់ដល់ មាតាបិតា អ្នកសំខាន់ៗ និង ដៃគូនៅក្នុងសហគមន៍ និងសហការជាមួយអង្គការនៅក្នុងសហគមន៍ និងអង្គការសាសនា។ ក្នុងគោលបំណងប្រើវិធីផ្សេងៗដើម្បីទាក់ទងទៅ សហគមន៍មាតាបិតាដែលមិនសូវចេះភាសាអង់គ្លេស ក្រុមអ្នកបម្រើ និង ក្រុមអ្នកគាំទ្រ មជ្ឈមណ្ឌលបកប្រែភាសា នៃការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និង សហគមន៍ (FACE) បន្តនូវការពង្រីកការបម្រើជាច្រើន ដែលរួមមាន ការរៀបចំតម្កល់ឯកសារបកប្រែ និង ទំព័រវ៉ិបសៃ ដែលមានប្រាំបួន (៩) ភាសា នៃការផ្សព្វផ្សាយដ៏ច្រើនបំផុតនៅក្នុងក្រសួង ដែលផ្តល់ព័ត៌មានជាភាសាទាំងនោះ។ www.philasd.org/language/khmer

- បច្ចុប្បន្ននេះ ការិយាល័យផ្នែក កម្មវិធី និង កម្មវិធីសក្សា ភាសាចម្រុះ សហការជាមួយអង្គការជាច្រើន ដើម្បីផ្តល់ កម្មវិធីក្រោយម៉ោងសិក្សា និង កម្មវិធីនៅរដូវក្តៅ សម្រាប់សិស្សានុសិស្សដែលត្រូវការរៀនភាសាអង់គ្លេស (ELLs)។ ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីកម្មវិធីទាំងនេះ និង/ឬ វិធីដើម្បីសហការជាមួយ ការិយាល័យផ្នែក កម្មវិធី និង កម្មវិធីសក្សា ភាសាចម្រុះ សូមទាក់ទងទៅ Diane J. Kim (dkim@philasd.org)។

- អង្គការនៅក្នុងសហគមន៍អាចទាក់ទងទៅ ការិយាល័យផ្នែក កម្មវិធី និង កម្មវិធីសិក្សា ភាសាចម្រុះ បើសិនជាពួកគេចង់ជួបជាមួយអ្នកតំណាងរបស់ការិយាល័យនេះ។ ការិយាល័យផ្នែក កម្មវិធី និង កម្មវិធីសិក្សា ភាសាចម្រុះ នឹងបើកអង្គប្រជុំនៅក្នុងសហគមន៍ តាមតំបន់ផ្សេងៗនៃទីក្រុង នៅខែក្រោយៗ។

**៣. តើយើងអាចបង្កើន ការជួល អ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា (BCAs) និង ដើម្បីឲ្យពួកគេធ្វើការនៅតាមសាលារបស់យើងទាំងអស់ ដោយវិធីណា?**

ការជួល អ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា (BCAs) គឺពឹងផ្អែកទៅលើថវិកាចំណាយទូទៅ (operating budget) និងប្រាក់ជំនួយពីរដ្ឋសហព័ន្ធ ដែលទទួលបានតាមរយៈច្បាប់ Title III។ ចាប់តាំងពីពេលដែលក្រសួងបានកាត់បន្ថយបុគ្គលិកក្នុងឆ្នាំ ២០១១ គេមិនទាន់បានជួល BCA ឲ្យមានចំនួនដូចដើមវិញនៅឡើយទេ (១០៣ នាក់)។ បច្ចុប្បន្ននេះ មាន BCAs ចំនួន ៥៧ នាក់។

**៤. តើការជួល BCAs ថែមទៀត (សាលាជាច្រើនមាន BCA តែមួយថ្ងៃក្នុងមួយសប្តាហ៍) និង អ្នកជួយបង្រៀនសិស្ស ESOL គឺជាភារៈកិច្ចដ៏សំខាន់របស់ គណកម្មាធិការកែទម្រង់សាលារៀន ដែរឬទេ?**

ការចាត់តាំង BCAs ធ្វើឡើងតាមការប្រើទិន្នន័យនៃភាសាដែលនិយាយនៅផ្ទះរបស់ក្រសួង (របាយការណ៍ផ្ទាល់ពីមាតាបិតា នៅពេលចុះឈ្មោះ អំពី ភាសានិយាយ និង ភាសាសរសេរ ដែលប្រើនៅផ្ទះ) ព្រមទាំងការផ្លាស់ប្តូរស្ថានភាពប្រជាជន ដែលបានចង្អុលបង្ហាញពីការមកដល់ទីក្រុងនៃជនភៀសខ្លួន។ ទោះជាយ៉ាងនេះក៏ដោយ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗដែលក្រុមគ្រួសារនិយាយភាសាចម្រុះកំពុងប្រឈមមុខ គឺការពង្រីកការគាំទ្រក្រុមគ្រួសារដែលនិយាយភាសាចម្រុះ ត្រូវមានកម្មវិធីផ្សេងៗបន្ថែម លើសពីការជួល BCAs ទៅទៀត។ អ្នកអប់រំនៅក្នុងក្រសួងទាំងអស់ ទទួលខុសត្រូវ ការអប់រំ និង ការគាំទ្រសិស្សានុសិស្ស និង ក្រុមគ្រួសាដែលនិយាយភាសាចម្រុះ។

**៥. តើលោកអ្នកមានជំហរដូចម្តេចចំពោះការអប់រំសិស្សដែលនិយាយពីរភាសា? ការស្រាវជ្រាវជាច្រើនបានឲ្យដឹងថា សិស្សានុសិស្សដែលនិយាយពីរភាសាទាំងនេះ មានការរីកចម្រើនតាមកម្រិតដែលចង់បាន និង ដោយឆាប់រហ័ស។ តើអ្វីៗទាំងនេះនឹងពង្រឹងការសហការដែរឬទេ បើសិស្សានុសិស្ស និង សាលា ប្រើភាសាកំណើតរបស់សិស្ស?**

ការិយាល័យផ្នែក កម្មវិធី និង កម្មវិធីសិក្សា ភាសាចម្រុះ កំពុងកែលម្អ និង ពង្រីក កម្មវិធីអប់រំសិស្សដែលនិយាយពីរភាសានៅក្នុងក្រសួងអប់រំ។ បច្ចុប្បន្ននេះ មានកម្មវិធីអប់រំសិស្សដែលនិយាយពីរភាសា ប្រាំ—កម្មវិធីអប់រំសិស្សដែលនិយាយពីរភាសានៃដំណាក់កាលផ្លាស់ប្តូរ បួន និង កម្មវិធីបង្រៀនជាពីរភាសា មួយ។ ឆ្នាំនេះ ការិយាល័យផ្នែក កម្មវិធី និង កម្មវិធីសិក្សា ភាសាចម្រុះ សហការជាមួយ Dr. Nelson Flores នៅសាកលវិទ្យាល័យ ផិនស៊ីលវេញ៉ា ដើម្បីផ្តល់ការហ្វឹកហ្វឺនផ្នែកការងារដល់គ្រូបង្រៀនសិស្សដែលនិយាយពីរភាសា សម្រាប់កម្មវិធីអប់រំសិស្សដែលនិយាយពីរភាសារបស់យើងទាំងអស់។ ការហ្វឹកហ្វឺនផ្នែកការងាររួមមាន សិក្ខាសាលានៅថ្ងៃសៅរ៍ ដែលណែនាំគ្រូអំពីកម្មវិធីថ្មីៗ នៃការអប់រំសិស្សដែលនិយាយពីរភាសា និងជំនួយនៅសាលា នៅពេលដែលពួកគេចាប់ផ្តើមអនុវត្តផែនការនៃគំនិតផ្ទាល់ខ្លួន ដែលស្របទៅតាមអ្វីៗដែលមាននៅក្នុងសិក្ខាសាលាទាំងនោះ។

កម្មវិធីបង្រៀនជាពីរភាសា និង កម្មវិធីអប់រំសិស្សដែលនិយាយពីរភាសាសម្រាប់ដំណាក់កាលផ្លាស់ប្តូរ ទាំងអស់របស់យើង គឺភាសា អេស្ប៉ាញ៉ុល/អង់គ្លេស។

សាលាដូចតទៅនេះ ផ្តល់ការអប់រំសម្រាប់សិស្សដែលនិយាយពីរភាសានៃដំណាក់កាលផ្លាស់ប្តូរ៖

សាលា Alexander McClure
600 W. Hunting Park Avenue
Philadelphia, PA 19140
Phone: 215-456-3001

សាលា Cayuga
4344-4358 N. 5th Street
Philadelphia, PA 19140
Phone: 215-456-3167

សាលា Lewis Elkin l
3199 D Street
Philadelphia, PA 19134
Phone: 215 291-4701

សាលា Bayard Taylor
3698 N. Randolph Street
Philadelphia, PA 19140
Phone: 215-227-4435

សាលានេះផ្តល់ កម្មវិធីសិក្សាជាពីរភាសា៖

សាលា Hon. Luis Muñoz-Marin l
3300 North 3rd Street
Philadelphia PA, 19140

**៦. លើសពីនេះទៀត តាមគំនិតរបស់លោកអ្នក តើសហគមន៍ដូចម្តេចដែរទៅ? យើងនិយាយថា យើងជាអ្នកទាក់ទងជាមួយមាតាបិតា ប៉ុន្តែខ្ញុំដូចជាមិនសូវឃើញបែបនេះសោះ ជាទូទៅមាតាបិតាទេដែលជាអ្នកទាក់ទងមកសាលា។**

ការិយាល័យផ្នែក កម្មវិធី និង កម្មវិធីសិក្សា ភាសាចម្រុះ នឹងចាប់ផ្តើមរៀបចំអង្គប្រជុំជាប្រចាំ ដែលបើកឲ្យអ្នកសំខាន់ៗទាំងអស់ចូលរួម។ ព័ត៌មានអំពីអង្គប្រជុំលើកទីមួយសម្រាប់អ្នកសំខាន់ៗមាននៅត្រង់នេះ (អង្គប្រជុំជាមួយអ្នកសំខាន់ៗ)។ នៅក្នុងអង្គប្រជុំទាំងនេះ យើងខ្ញុំនឹងរៀបចំបង្កើតវិធីផ្សេងៗ ដែលក្រសួងកាន់តែសកម្មក្នុងការធ្វើទំនាក់ទំនងជាមួយ មាតាបិតា និង ដៃគូនៅក្នុងសហគមន៍។

**៧. តើការ កាត់បន្ថយចំនួនសិស្សសម្រាប់គ្រូ ESOL គឺជាភារៈកិច្ចសំខាន់របស់ SRC ដែរឬទេ? គ្រូខ្លះមានសិស្សជាង៥០នាក់។**

ការិយាល័យផ្នែក កម្មវិធី និង កម្មវិធីសិក្សា ភាសាចម្រុះ ចាត់តាំងគ្រូ ESOL ឲ្យទៅតាមសាលា ដោយយោងទៅលើចំនួនសិស្ស ELLs និងកម្រិតនៃចំណេះដឹងផ្នែកភាសាអង់គ្លេសរបស់សិស្ស ELLs នៅសាលានោះ។ គ្រូ ESOLs សហការជាមួយ គ្រូប្រចាំថ្នាក់ និង គ្រូបង្រៀនមុខវិទ្យាសំខាន់ៗ ដើម្បីបង្កើន និង គាំទ្រ ការសិក្សារបស់សិស្ស ELLs—នេះជាការចែករំលែកការទទួលខុសត្រូវ។ ព័ត៌មានបន្ថែមអំពី មុខនាទី និង ការទទួលខុសត្រូវរបស់គ្រូ ESOLs មាននៅក្នុង <u>កូនសៀវភៅសម្រាប់កម្មវិធីសិក្សារបស់សិស្ស ELLs</u> ដែលអាចចម្លងយកពីវិបសៃនេះ៖ http://webgui.phila.k12.pa.us/offices/m/multilingual-education/policies--procedures

**៨. សូមពន្យល់អំពីគំនូសតារាងដែលនៅក្នុងទិន្នន័យនៃការប្រឡង ACCESS ។ ហេតុអ្វីបានជាក្រសួងកាត់បន្ថយចំនួនភាគរយនៃសិស្ស ELLs ដែលសម្រេចបានតាមកម្រិតនៃការប៉ិនប្រសប់ និង ការរីកចម្រើន ផ្នែកភាសាអង់គ្លេស?**

ក្នុងខណៈដែលយើងធ្វើបានលើសពីការកំណត់របស់ ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា ក្នុងរយៈពេលបីឆ្នាំកន្លងទៅនេះ ទិន្នន័យនៃការប្រឡង ACCESS ទូទាំងក្រសួងរបស់យើង បង្ហាញឲ្យឃើញថា ចំនួនសិស្សដែលសម្រេចបានការប៉ិនប្រសប់ក្នុងការសិក្សាភាសាអង់គ្លេស និង មានការរីកចម្រើនក្នុងការសិក្សាភាសាអង់គ្លេស មានការចុះថយបន្តិច។ ក្នុងការឆ្លើយតបទៅនឹងការចុះថយនេះ ការិយាល័យផ្នែក កម្មវិធី និង កម្មវិធីសិក្សា ភាសាចម្រុះ សហការជាមួយនាយកសាលា និង គ្រូ ដើម្បីវិភាគទិន្នន័យនៃការប្រឡង ACCESS ជាមួយនឹងទិន្នន័យផ្សេងៗទៀត ដើម្បីផ្តល់ជាដំណឹងដល់ការសម្រេចចិត្ត ក្នុងការបង្ហាត់បង្រៀន និង ការសម្រេចចិត្តអំពីកម្មវិធី នៅតាមសាលា។ លើសពីនេះទៀត ទិន្នន័យនៃការប្រឡង ACCESS បានប្រើនៅថ្នាក់ក្រសួង ដើម្បីផ្តល់ជាដំណឹងក្នុងការសម្រេចចិត្ត ដែលទាក់ទងនឹងការហ្វឹកហ្វឺនផ្នែកការងារសម្រាប់គ្រូ និង ច្បាប់នៃការបង្ហាត់បង្រៀនទូទាំងក្រសួង។

**៩. បើនិយាយអំពីការវាយតម្លៃ តើនៅពេលណាទើបយើងនឹងបន្តការសន្ទនាអំពីសិស្ស ELLs និងការវាយតម្លៃដែលសក្តិសម?**

ការិយាល័យផ្នែក កម្មវិធី និង កម្មវិធីសិក្សា ភាសាចម្រុះ នឹងចាប់ផ្តើមរៀបចំអង្គប្រជុំជាប្រចាំ ដែលបើកឲ្យអ្នកសំខាន់ៗទាំងអស់ចូលរួម។ ព័ត៌មានអំពីអង្គប្រជុំលើកទីមួយសម្រាប់អ្នកសំខាន់ៗមាននៅត្រង់នេះ (អង្គប្រជុំជាមួយអ្នកសំខាន់ៗ)។ នៅក្នុងអង្គប្រជុំនេះ យើងនឹងពិនិត្យគ្រប់ប្រធានបទនៃការបារម្ភទាំងអស់ ដែលបានលើកឡើងនៅក្នុងអង្គប្រជុំរបស់ SPP។ ផែនការរបស់យើងគឺបន្តការសន្ទនាតាមរយៈការប្រជុំជាមួយអ្នកសំខាន់ៗឲ្យបានទៀងទាត់ ព្រមទាំងប្រមូលមតិយោបល់ដែលអាចផ្តល់ជាព័ត៌មានដល់ការសម្រេចចិត្តរបស់ ការិយាល័យផ្នែក កម្មវិធី និង កម្មវិធីសិក្សា ភាសាចម្រុះ។

**១០. តើយើងអាចធ្វើយ៉ាងណាដើម្បីឲ្យ ក្រសួងអប់រំ មើលឃើញ និងចាត់ទុក សិស្ស ELLs និងសិស្សានុសិស្សដែលនិយាយភាសាចម្រុះ ថាជាគុណសម្បត្តិរបស់ ក្រសួង និង របស់សហគមន៍ យើង ជាជាងចាត់ទុកពួកគេថាជាបន្ទុក?**

មានអ្នកអប់រំជាច្រើននៅក្នុងក្រសួងអប់រំ ដែលបានឲ្យតម្លៃ និងទទួលស្គាល់ វប្បធម៌ និង ភាសា ដែលសិស្សានុសិស្សនិយាយភាសាចម្រុះ របស់យើងនាំមក សាលា និងសហគមន៍ របស់យើង។ ទោះជាយ៉ាងនេះក្តី ដោយសារមូលហេតុផ្សេងៗ ដែលអ្នកអប់រំមួយចំនួនបានប្រឈមមុខនឹងឧបសគ្គជាច្រើនក្នុងការតម្រូវទៅតាមសេចក្តីត្រូវការរបស់សិស្ស ELLs ហើយមិនបានចាប់អារម្មណ៍នូវគុណសម្បត្តិទាំងនេះ។ ដើម្បីដោះស្រាយការបារម្ភទាំងនេះ យើងបានអញ្ជើញលោកគ្រូអ្នកគ្រូ ឲ្យមកចូលរួមក្នុងការហ្វឹកហ្វឺនផ្នែកការងារផ្សេងៗ ដែលរៀបចំឡើងដោយ ការិយាល័យផ្នែក កម្មវិធី និង កម្មវិធីសិក្សា ភាសាចម្រុះ និង ការិយាល័យគាំទ្រក្រុមគ្រួសារដែលនិយាយភាសាចម្រុះ។ ការហ្វឹកហ្វឺនទាំងនេះ ផ្តល់ឱកាសឲ្យគ្រូស្វែងយល់ថែមទៀតអំពី ការដែលនិយាយពីរភាសា វប្បធម៌ខុសប្លែកៗគ្នា និង ព័ត៌មានអំពីវិធីបម្រើសិស្ស ELLs និងសិស្សានុសិស្សដែលនិយាយភាសាចម្រុះ។ វិធីផ្សេងទៀតដែលសាលាអាចធ្វើដើម្បីដោះស្រាយការបារម្ភទាំងនេះ គឺសហការជាមួយអង្គការនៅក្នុងសហគមន៍ ដែលចង់ចែករំលែកនូវចំណេះដឹងផ្នែក វប្បធម៌ និង ភាសា របស់ពួកគេ ជាមួយនឹងបុគ្គលិករបស់សាលា។ យើងខ្ញុំសង្ឃឹមថា តាមរយៈអង្គប្រជុំជាមួយ សហគមន៍ និង អ្នកសំខាន់ៗ ក្នុងពេលខាងមុខនេះ អាចជួយដល់ការសហការគ្នាបាន។

**១១.តើក្រសួងបានធ្វើអ្វីខ្លះ ដើម្បីកែលម្អអាហារថ្ងៃត្រង់របស់សាលា?**

ការិយាល័យ ផ្នែកបម្រើម្ហូបអាហារ មានព័ត៌មានលម្អិតអំពីអាហារថ្ងៃត្រង់របស់សាលា។ ការិយាល័យនេះក៏ផ្តល់ជាយោបល់ជូនដល់ មាតាបិតា និង សិស្សានុសិស្ស ណាដែលចង់កែលម្អអាហារថ្ងៃត្រង់របស់សាលា។ ដើម្បីជ្រាបព័ត៌មានបន្ថែម និង អានសំណួរដែលគេឧស្សាហ៍សួរ សូមមើលវិបសៃ http://webgui.phila.k12.pa.us/uploads/ZF/2S/ZF2SPZ7dfD4mv1adSc_3mg/Nutrition-Program-FAQs.pdf

## យោបល់របស់អ្នកចូលរួមប្រជុំ៖

១. យប់នេះ អ្នកទាំងអស់ – សិស្សានុសិស្ស និងមនុស្សពេញវ័យ – បាននិយាយអំពីសារៈសំខាន់នៃការធ្វើទំនាក់ទំនងជាមួយសិស្ស ELLs។ ខ្ញុំសង្ឃឹមថា សមាជិករបស់ SRC និង លោក Kihn នឹងគិតដល់ចំណុចសំខាន់ទាំងនេះ នៅពេលដែលពួកគាត់បន្តការចាត់តាំងគ្រូពីកន្លែងមួយទៅកន្លែងមួយទៀត ហើយធ្វើឲ្យទំនាក់ទំនងទាំងនេះមានការប្រេះឆា នៅពេលដែលពួកគាត់បង្កើត ការផ្លាស់ប្តូរសាលា និង សាលាឆាផ់ដែលត្រូវការកែលម្អប្រព័ន្ធសិក្សាជាថ្មី បន្ថែមទៀត។

២. ខ្ញុំបារម្ភដល់ក្រុមគ្រួសារវៀតណាមយ៉ាងខ្លាំង ដោយសារពួកគេមិនបានទទួលជំនួយគ្រប់គ្រាន់ពី អ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា ដែលជាជនជាតិវៀតណាម។ សិស្សានុសិស្សទទួលជំនួយតិចតួចបំផុត ដោយសារអ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា ដែលជាជនជាតិវៀតណាម ធ្វើការនៅសាលាតែមួយថ្ងៃក្នុងមួយសប្តាហ៍។ យើងត្រូវការ អ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា ដែលជាជនជាតិវៀតណាម ធ្វើការនៅសាលាឲ្យបានច្រើនថ្ងៃ។ មាន អ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា ដែលជាជនជាតិវៀតណាមតែ ៥ នាក់គត់ នៅក្នុងក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាទាំងមូល។

**សូមមើលចម្លើយដែលបានឆ្លើយតបទៅនឹងសំណួរលេខ៣ ដែលទាក់ទងនឹង BCAs ។*